# កិច្ចព្រមព្រៀងគម្រោងការ

រវាង

ក្រសួងអប់រំ យុវជន និងកីឡា
នៃព្រះរាជាណាចក្រកម្ពុជា

និង

សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ
(មណ្ឌលសិក្សាឡាតាស្តី)

# សង្ខេបគម្រោងកម្មវិធី

❖ ឈ្មោះគម្រោង ៖ អប់រំ

❖ ស្ថាប័នអនុវត្តគម្រោង ៖ សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ

❖ អាសយដ្ឋាន ៖ ប្រអប់សំបុត្រ ០១០៦ ភូមិខ្លាកូនថ្មី សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ
ខេត្តបន្ទាយមានជ័យ
លេខទំនាក់ទំនង៖ ០៥៤ ៦៤៤១ ៤៤៤ / ០១២ ៥០៨ ៧៦៤
សាអេឡិចត្រូនិច៖ **opdir.lataste@gmail.com**

❖ អ្នកផ្តល់ជំនួយសំខាន់ ៖ **AEC-Foyer Lataste** (ប្រទេសបារាំង)

❖ ទីកន្លែងអនុវត្តគម្រោង ៖ ខេត្តបន្ទាយមានជ័យ បាត់ដំបង សៀមរាប និងរាជធានីភ្នំពេញ

❖ ថិរវេលារបស់គម្រោង ៖ រយៈពេល ៣ឆ្នាំ

❖ ថវិកាគម្រោងសរុបមាន ៖ **៤១៤.២៤៨** ដុល្លារសហរដ្ឋអាមេរិក

❖ ចំនួនបុគ្គលិកបរទេសបម្រើការនៅក្នុងគម្រោង ៖ ០១នាក់

❖ ចំនួនបុគ្គលិកខ្មែរបម្រើការនៅក្នុងគម្រោង ៖ ១១នាក់

❖ **គោលដៅនៃកិច្ចសហប្រតិបត្តិការ និងជំនួយការនៅក្នុងគម្រោងមាន៖**

១. ទ្រទ្រង់ផ្នែកហិរញ្ញវត្ថុដល់សាលាបឋមសិក្សាសម្រស់កុមារ សម្រាប់ធ្វើឱ្យប្រសើរឡើងនូវប្រតិបត្តិការ និងការគ្រប់គ្រងល្អជាមួយលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សក្នុងសាលារៀននេះ។

២. ផ្តល់ការចូលរៀនដោយឥតគិតថ្លៃនៅមណ្ឌលសិក្សាបំប៉នបន្ថែម ដែលបង្កើតឡើងដោយសមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ សម្រាប់កុមារដែលមកពីគ្រួសារជួបការលំបាក។

៣. ផ្តល់ការស្នាក់នៅដល់សិស្សានុសិស្សវិទ្យាល័យ ដែលមានផ្ទះនៅឆ្ងាយពីគ្រឹះស្ថានសិក្សា អាចស្នាក់នៅ និងទទួលបាននូវការគាំទ្រនៅក្នុងមណ្ឌលសិក្សាសម្រាប់បន្តការសិក្សារបស់ពួកគេ ឱ្យកាន់តែមានភាពល្អប្រសើរឡើង។

៤. គាំទ្រយុវជនដែលងាយរងគ្រោះនៅខេត្តបន្ទាយមានជ័យ និងផ្តល់ការបណ្តុះបណ្តាលថ្នាក់ឧត្តមសិក្សា ឬសាលា / មណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងតាមរោងជាងនានានៅក្រុងសិរីសោភ័ណ ខេត្តសៀមរាប ខេត្តបាត់ដំបង ឬរាជធានីភ្នំពេញ។

៥. អភិវឌ្ឍគម្រោងក្នុងខេត្តដែលទាក់ទងជាមួយការបណ្តុះបណ្តាលវិជ្ជាជីវៈ នៅតាមហាង ឬតាមរោងជាង ដើម្បីធ្វើឱ្យប្រសើរឡើងរាល់លក្ខខណ្ឌនៃការរស់នៅ ក្នុងគ្រួសារជួបកាលំបាករបស់គេ និងធ្វើឱ្យមានស្ថិរភាពជំនាញវិជ្ជាជីវៈដល់យុវជននាពេលអនាគត។

# ពណ៌នាអំពីកម្មវិធីគម្រោង

សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវជនខ្មែរ (សអបយខ) ជាអង្គការមិនមែនរដ្ឋាភិបាល មិនរកប្រាក់កម្រៃ ដែលមានជំនាញក្នុងការការពារ និងអភិវឌ្ឍកុមារងាយរងគ្រោះនៅក្នុងប្រទេសកម្ពុជា។ សមាគមយើងឯករាជ្យ មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍របស់គណបក្សនយោបាយ ក្នុងនោះក៏មិនផ្តល់ជាសម្ភារៈ ហិរញ្ញវត្ថុ ធនធានមនុស្ស គាំទ្រគណបក្សនយោបាយ បេក្ខជននយោបាយ ឬអ្នកគាំទ្រណាមួយឡើយ។ ចាប់តាំងពីឆ្នាំ១៩៩៤ យើងធ្វើការដើម្បីជួយកុមារ និងគ្រួសាររបស់ពួកគេនៅក្នុងខេត្តបន្ទាយមានជ័យ ដើម្បីលើកកម្ពស់ស្វ័យភាពរបស់ពួកគេ ដោយពួកគេទទួលបានការអប់រំសុខភាព និងវប្បធម៌។ កុមារក្រីក្រ ចំនួនជិត៩០០ នាក់ ត្រូវបានជួយដោយក្រុមបុគ្គលិកខ្មែរក្នុងស្រុក ដោយគោរពនូវវប្បធម៌ និងសេចក្តីថ្លៃថ្នូររបស់ពួកគេ។

## ១. ជីវប្រវត្តិ

សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវជនខ្មែរ ត្រូវបានបង្កើតឡើងនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៩៤។ ជាដំបូងសកម្មភាពចម្បងរបស់សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវជនខ្មែរ គឺផ្តោតលើការបង្កើតនូវការបណ្តុះបណ្តាលវិជ្ជាជីវៈដល់យុវជនតែប៉ុណ្ណោះ។ សកម្មភាពអប់រំថ្មី បានចាប់ផ្តើមនៅឆ្នាំ២០០១ ដោយមានការស្ថាបនា និងការឧបត្ថម្ភដល់ **"សាលាបឋមសិក្សាសម្រស់កុមារ"**។ ចាប់តាំងពីឆ្នាំ២០០១ ដល់ឆ្នាំ២០១៥ កម្មវិធីផ្សេងៗទៀត ត្រូវបានបង្កើតឡើងដោយយោងទៅលើតម្រូវការជាក់ស្តែង ដែលកើតមាននៅពេលនោះ។

ចាប់តាំងពីឆ្នាំ២០១៥ រហូតមកដល់បច្ចុប្បន្ន **សអបយខ** កំពុងដំណើរការគម្រោងចំនួន ៥ ក្នុងវិស័យអប់រំ៖

១. គម្រោងជួយឧបត្ថម្ភដំណើរការសាលាបឋមសិក្សាសម្រស់កុមារ

២. គម្រោងសាលារៀនបំប៉នបន្ថែម

៣. គម្រោងសិស្សស្នាក់នៅ (អន្តេវាសិកដ្ឋាន)

៤. គម្រោងឆ្ពោះទៅរកជីវិតការងារ និងគាំទ្រសម្រាប់ការអប់រំនៅឧត្តមសិក្សា និង

៥. គម្រោងការបណ្តុះបណ្តាលវិជ្ជាជីវៈ

នៅក្នុងឆ្នាំ២០១៥ សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវជនខ្មែរ បានរៀបចំឡើងវិញនូវកម្មវិធីអប់រំរបស់សមាគម ដោយចាប់ផ្តើមពីនីតិវិធី ដែលធ្វើឱ្យមានអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា។

## ២. គោលដៅ និងបេសកកម្ម

កម្មវិធីអប់រំរបស់សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវជនខ្មែរ មានគោលបំណងផ្តល់ជូនកុមារងាយរងគ្រោះទាំងអស់ឱ្យទទួលបានការអប់រំប្រកបដោយគុណភាព និងឥតគិតថ្លៃ។ សមាគមមានបេសកកម្មដូចខាងក្រោម៖

- **គម្រោងជួយឧបត្ថម្ភដំណើរការសាលាបឋមសិក្សាសម្រស់កុមារ៖** ធ្វើប្រតិបត្តិការគាំទ្រដល់សាលាបឋមសិក្សានេះ ដើម្បីធានាឱ្យមានការអប់រំប្រកបដោយគុណភាព។

- **គម្រោងសាលារៀនបំប៉នបន្ថែម៖** គាំទ្រ និងរៀបចំថ្នាក់បង្រៀន ធ្វើឱ្យពួកគេអាចចូលរៀនសូត្របាន សម្រាប់សិស្សទាំងអស់គ្នា និងការអភិវឌ្ឍវិធីសាស្ត្របង្រៀនមួយចំនួន។
- **គម្រោងសិស្សស្នាក់នៅ (អន្តេវាសិកដ្ឋាន)៖** គាំទ្រសិស្សចំនួន ១៥ ទៅ ២០ នាក់ ដែលមានភូមិសាស្ត្រនៅដាច់ស្រយាលពីសាលារៀន និងខ្វះមធ្យោបាយក្នុងការបន្តការសិក្សានៅថ្នាក់វិទ្យាល័យ។
- **គម្រោងឆ្ពោះទៅរកជីវិតការងារ និងគាំទ្រសម្រាប់ការអប់រំនៅឧត្តមសិក្សា៖** គាំទ្រនិស្សិតចំនួន ៣០ នាក់នៅឧត្តមសិក្សានៅរាជធានីភ្នំពេញ ខេត្តសៀមរាប បាត់ដំបង និងបន្ទាយមានជ័យ។
- **គម្រោងការបណ្តុះបណ្តាលវិជ្ជាជីវៈ៖** គាំទ្រយុវជនដែលបោះបង់ការសិក្សា ហើយមានទស្សនៈអស់សង្ឃឹមទាក់ទងទៅនឹងអនាគតរបស់ពួកគេ។

## ៣. ទិសាលភាពគម្រោងកម្មវិធី

កម្មវិធីអប់រំរបស់សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ គ្របដណ្តប់នៅទូទាំងខេត្តបន្ទាយមានជ័យ ដោយអនុវត្តសកម្មភាពក្នុងឃុំចំនួន១៤ នៃស្រុក/ក្រុងទាំង ០៩។ លើសពីនេះ សមាគមបានបញ្ជូនអ្នកទទួលផលពីកម្មវិធីអប់រំ ដែលមកពីខេត្តបន្ទាយមានជ័យឱ្យបន្តការសិក្សានៅខេត្តសៀមរាប បាត់ដំបង និងរាជធានីភ្នំពេញ។

## ៤. សកម្មភាពគម្រោងម្មវិធី

សកម្មភាពគម្រោងកម្មវិធីអប់រំរបស់សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ បាននិងកំពុងបន្តអនុវត្ត នៅមណ្ឌលសិក្សាឡាតាស្តី ដូចខាងក្រោម៖

១. ជួយឧបត្ថម្ភដល់ដំណើរការសាលាបឋមសិក្សាសម្រស់កុមារ។

២. ផ្តល់សេវារៀនបន្ថែមដោយឥតគិតថ្លៃដល់សិស្សានុសិស្សចាប់ពីថ្នាក់បឋមសិក្សាដល់ថ្នាក់វិទ្យាល័យ។

៣. ឧបត្ថម្ភ និងផ្តល់អន្តេវាសិកដ្ឋានដល់សិស្សក្រីក្រដែលរស់នៅតំបន់ដាច់ស្រយាល និងឆ្ងាយពីវិទ្យាល័យ។

៤. ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ ដើម្បីបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅសាកលវិទ្យាល័យ និងសាលាជំនាញនានា។

៥. ជួយឧបត្ថម្ភដល់យុវជនដែលបោះបង់ការសិក្សា ឬមកពីគ្រួសារក្រីក្រ ឱ្យបានចូលរៀនមុខវិជ្ជាជីវៈនៅតាមហាង ឬតាមរោងជាងក្នុងក្រុងសិរីសោភ័ណ។

៦. ផ្តល់គំនិតអប់រំផ្នែកបរិស្ថាន លើកកម្ពស់ការធ្វើកសិកម្មចំរុះប្រកបដោយចីរភាព និងជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញ៖
   - រៀបចំសិក្ខាសាលា ស្តីពីកសិកម្មសរីរាង្គនៅក្នុងសួនបន្លែរបស់សមាគម។
   - រៀបចំសកម្មភាពនានានៅក្នុងកសិដ្ឋានដីស្រែរបស់សមាគម។

៧. ផ្តល់សេវាអប់រំវប្បធម៌ដូចជា៖

- ផ្តល់ការសិក្សាមុខវិជ្ជារបាំប្រពៃណីខ្មែរដល់កុមារ និងយុវជនក្នុងគម្រោង។
- សិក្ខាសាលាអំពីការច្នៃប្រឌិត ការកែច្នៃរបស់ប្រើប្រាស់រួចហើយឡើងវិញ ការគូររូប និងការតុបតែងផ្សេងៗ។
- ផ្តល់ឱកាសដល់កុមាររស់នៅក្នុងមណ្ឌល និងសហគមន៍ជុំវិញទទួលបានការអានសៀវភៅ និងរៀនកុំព្យូទ័រថ្នាក់មូលដ្ឋាន។
- កុមារ និងយុវជនទទួលបានការមើលខ្សែភាពយន្តខ្មែរ និងបរទេស ឬវីឌីអូអំពីសកម្មភាពសមាគមជារៀងរាល់មួយខែម្តង។
- សិក្ខាសាលាអំពីក្បាច់គុណបុរាណខ្មែរ តែក្វាន់ដូ សៀករហ័សកម្ម និងសកម្មភាពកំសាន្តផ្សេងៗ។

## ៥. ក្រុមគោលដៅ ឬអ្នកទទួលផល

សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ មានគោលបំណងគាំទ្រដល់ការអប់រំរបស់កុមារ និងយុវជនខ្មែរគ្រប់រូប ដែលផ្តល់អាទិភាពដល់កុមារកំព្រា កុមារងាយរងគ្រោះ និងយុវជនមកពីគ្រួសារក្រីក្ររស់នៅក្នុងខេត្តបន្ទាយមានជ័យ។

## លក្ខខណ្ឌលម្អិត

## ក្រសួងអប់រំ យុវជន និងកីឡា

## និង

## សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ

## បានព្រមព្រៀងដូចខាងក្រោមនេះ៖

### មាត្រា ១

### លក្ខខណ្ឌទូទៅនៃកិច្ចព្រមព្រៀង

១.១ កិច្ចព្រមព្រៀងនេះធ្វើឡើងក្រោមកិច្ចសហប្រតិបត្តិការរវាងក្រសួងអប់រំ យុវជន និងកីឡា និងសមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ ទាំងការអនុវត្ត និងការវាយតម្លៃលើសកម្មភាពទាំងមូលរបស់គម្រោង ដើម្បីឱ្យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

១.២ រាល់ការអនុវត្តកម្មវិធី ត្រូវបានពិភាក្សាជាមួយនឹងមន្ទីរជំនាញថ្នាក់ក្រោមជាតិដែលមានការពាក់ព័ន្ធ។

១.៣ រាល់ការសាងសង់សំណង់ណាមួយ ត្រូវធ្វើការពិភាក្សាយ៉ាងលម្អិតជាមួយក្រសួងអប់រំ យុវជន និងកីឡា ជាមុនសិនទើបអាចដំណើរការបាន។ រាល់គម្រោង និងប្លង់សាងសង់ រួមទាំងក្បាច់រចនា ត្រូវធ្វើឡើងស្របតាមការណែនាំរបស់ក្រសួងជំនាញ។

១.៤ កាលបរិច្ឆេទនៃគម្រោងចាប់ពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០២០ នឹងបន្តរហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៣។

១.៥ ក្នុងភាពជាដៃគូការងារ ក្រសួងអប់រំ យុវជននិងកីឡា និងសមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ បានឯកភាពគ្នា ថានឹងធ្វើការពិនិត្យឡើងវិញលើគម្រោងនេះ យ៉ាងតិច៣ខែមុនកាលបរិច្ឆេទបញ្ចប់នៃគម្រោង។ ក្រោយពីបានពិនិត្យ និងពិភាក្សាគ្នារួចហើយ សេចក្តីសម្រេចរួមគ្នានេះនឹងត្រូវធ្វើឡើង ថាតើត្រូវបញ្ចប់គម្រោងតាមពេលកំណត់ ឬក៏ស្វែងរកកិច្ចបន្តគម្រោងនេះមួយរយៈបន្ថែមទៀត។

១.៦ កិច្ចព្រមព្រៀងនេះត្រូវបានប្រើប្រាស់ជាផ្លូវការដោយក្រសួងអប់រំ យុវជន និងកីឡា និងសមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ សម្រាប់ជាមូលដ្ឋានក្នុងការធ្វើសហប្រតិបត្តិការក្នុងការងារ។

# មាត្រា ២

## សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ បានព្រមព្រៀងៈ

២.១ គោរពតាមគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា និងគោរពទំនៀមទម្លាប់ប្រពៃណីវប្បធម៌របស់ប្រជាជនកម្ពុជា។

២.២ អនុវត្តការងារដើម្បីសម្រេចនូវទិសដៅរបស់គម្រោងដាក់លាក់ដូចខាងក្រោមៈ

- ផ្តល់ឱ្យកុមារ និងយុវជនគ្រប់រូប ឱ្យទទួលបាននូវការអប់រំប្រកបដោយគុណភាពខ្ពស់ និងឥតគិតថ្លៃ។
- ជំរុញ និងធ្វើឱ្យរីកចម្រើន ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា លើដំណើរការសាលាបឋមសិក្សាសម្រស់កុមារ។
- ផ្តល់ការស្នាក់នៅក្នុងអន្តេវាសិកដ្ឋានក្នុងមណ្ឌលសិក្សាឡាតាស្ត៍ សម្រាប់សិស្សវិទ្យាល័យ ដែលមានលំនៅឋានឆ្ងាយពីគ្រឹះស្ថានសិក្សារបស់ពួកគេ។
- ផ្តល់កម្មវិធីសិក្សាបន្ថែមដោយឥតបង់ថ្លៃសម្រាប់កុមារនៅក្នុងតំបន់ អាចចូលសិក្សាបន្ថែមគ្រប់មុខវិជ្ជាដែលបានបង្រៀនពីបឋមសិក្សា ដល់ថ្នាក់វិទ្យាល័យ។
- ផ្តល់អាហារូបករណ៍ដល់យុវជនមកពីគ្រួសារជួបការលំបាក ឬស្ថានភាពគ្រួសារលំបាកខ្លាំង (កុមារកំព្រា កុមារអនាថា ឬកុមារដែលមានការរំលោភបំពាន) និងតាមដានពួកគេរហូតដល់មានការងារធ្វើ។
- ចូលរួមចំណែកអភិវឌ្ឍការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់យុវជន យុវនារី នៅខេត្តបន្ទាយមានជ័យដែលជួបការលំបាកក្នុងការសិក្សា ឬមានបំណងរៀនមុខរបរបច្ចេកទេស។

២.៣ សហការធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងអប់រំ យុវជន និងកីឡា ដែលជាដៃគូការងារ ដើម្បីទទួលបានលទ្ធផលកម្រិតអតិបរមាក្នុងការផ្ទេរបច្ចេកទេស និងសមត្ថភាពគ្រប់គ្រង និងធ្វើផែនការដល់មន្ត្រីរាជការក្រសួង។

២.៤ រាល់ការបោះពុម្ព ឬឯកសារទាំងឡាយណាដែលបានមកពីសមទ្ធិផលរបស់គម្រោងនេះ ត្រូវដាក់ជូនក្រសួងផ្តល់យោបល់រួចហើយ នឹងត្រូវចាត់ទុកជាសម្បត្តិរួមគ្នារបស់សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ និងក្រសួងអប់រំ យុវជន និងកីឡា។

២.៥ ចូលរួមឱ្យបានទៀងទាត់នូវរាល់កិច្ចប្រជុំនីមួយៗ តាមការអញ្ជើញរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីសម្របសម្រួលសកម្មភាពរបស់គម្រោង ដែលកំពុងដំណើរការ ព្រមទាំងធ្វើការផ្លាស់ប្តូរព័ត៌មានគ្នា និងដោះស្រាយបញ្ហា ដើម្បីឈានទៅសម្រេចជោគជ័យតាមទិសដៅរបស់គម្រោង។

២.៦ គម្រោងថវិកាដែលបានអនុម័ត ត្រូវប្រើប្រាស់ឱ្យមានប្រសិទ្ធភាពតាមទិសដៅដូចបានកំណត់៖

| គម្រោងចំណាយ (គិតជាដុល្លាអាមេរិក) | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | សរុប |
|---|---|---|---|---|
| ប្រាក់ខែបុគ្គលិកខ្មែរ | ៣៤.២៧២ | ៣៥.៣០០ | ៣៦.៣៥៩ | **១០៥.៩៣១** |
| ប្រាក់ខែបុគ្គលិកបរទេស | ១.៧០៧ | ១.៧៥៨ | ១.៨១១ | **៥.២៧៦** |
| ចំណាយការិយាល័យ | ៥០០ | ៧០០ | ៥០០ | **១.៧០០** |
| **សរុបចំណាយមិនផ្ទាល់** | **៣៦.៤៧៩** | **៣៧.៧៥៨** | **៣៨.៦៧០** | **១១២.៩០៧** |
| សាលាសម្រស់កុមារ | ១.៤៥០ | ១.៤៥០ | ១.៤៥០ | **៤.៣៥០** |
| សាលាបំប៉នបន្ថែម | ១៩.៨៨៥ | ២០.៤៨២ | ២១.០៩៦ | **៦១.៤៦៣** |
| អន្តេវាសិកដ្ឋាន | ២៤.៨០៦ | ២៥.៥៥០ | ២៦.៣១៦ | **៧៦.៦៧២** |
| គាំទ្រការសិក្សានៅឧត្តមសិក្សា | ២៧.០៣០ | ៣១.៤៣០ | ៣៥.៤៣០ | **៩៣.៨៩០** |
| បណ្តុះបណ្តាល វិជ្ជាជីវៈ | ១៨.០៥០ | ១៨.០៥០ | ១៨.៥០០ | **៥៤.៦០០** |
| អប់រំបរិស្ថាន | ៦.០៣៩ | - | - | **៦.០៣៩** |
| អប់រំវប្បធម៌ | ១.៤០០ | ១.៤៤២ | ១.៤៨៥ | **៤.៣២៧** |
| **សរុបចំណាយផ្ទាល់** | **៩៨.៦៦០** | **៩៨.៤០៤** | **១០៤.២៧៧** | **៣០១.៣៤១** |
| **ថវិកាគម្រោងសរុប** | **១៣៥.១៣៩** | **១៣៦.១៦២** | **១៤២.៩៤៧** | **៤១៤.២៤៨** |

២.៧ ផ្តល់ឱ្យក្រសួងអប់រំ យុវជន និងកីឡា(នាយកដ្ឋានជំនាញ និងមន្ទីអប់រំ យុវជន និងកីឡា ថ្នាក់ក្រោមជាតិពាក់ព័ន្ធ) នូវរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ ដោយផ្អែកលើប្រតិទិនរួមមាន៖

- របាយការណ៍សកម្មភាព និងការរីកចម្រើនរបស់គម្រោង
- បញ្ហានានាដែលពាក់ព័ន្ធនឹងការអនុវត្តគម្រោង
- ការចំណាយថវិកាគម្រោង(តាមប្រភេទដូចមានចែងនៅក្នុងតារាង)និង
- ព័ត៌មានអំពីចំនួនបុគ្គលិកជាតិ និងបុគ្គលិកបរទេស ព្រមទាំងតួនាទីរបស់ពួកគេ។

# មាត្រា ៣

## ក្រសួងអប់រំ យុវជន និងកីឡា បានព្រមព្រៀងៈ

៣.១ ចាត់តាំងបុគ្គលិកដែលមានលក្ខណៈសម្បត្តិ និងសមត្ថភាពសមស្រប (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) ឱ្យបំពេញការងារជាមួយសមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ ដើម្បីឱ្យសកម្មភាពអនុវត្តទៅមានប្រសិទ្ធភាព និងទាន់ពេលវេលា។

៣.២ អនុញ្ញាតឱ្យសមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ អាចជួលបុគ្គលិកកម្ពុជាធ្វើការបាន ដោយអនុលោមតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។

៣.៣ សម្របសម្រួលក្នុងករណីចាំបាច់ដល់ការសុំទិដ្ឋាការស្នាក់នៅឱ្យបុគ្គលិក និងទីប្រឹក្សាសមាគម ដែលចូលរួមក្នុងសកម្មភាពគម្រោង ដែលត្រូវបានទទួលស្គាល់តាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ។

៣.៤ បង្កើនប្រសិទ្ធភាព និងតម្លាភាពការងាររបស់អង្គភាពជំនាញនៅមូលដ្ឋាន ដែលគាំទ្រដោយគម្រោងនេះ ដោយធានាយ៉ាងណាឱ្យសមាគម ទទួលបានព័ត៌មានទាន់ពេលវេលាស្តីពីការប្រើប្រាស់ថវិកា និងសកម្មភាព។

៣.៥ ធានាថាក្រសួងនឹងជំរុញឱ្យមន្ត្រីជំនាញថ្នាក់ក្រោមជាតិ ធ្វើការប្រាស្រ័យទាក់ទងឱ្យបានជិតស្និតជាមួយសមាគមដើម្បីជួយកសាងផែនការ ការគ្រប់គ្រង និងដោះស្រាយបញ្ហា។

៣.៦ រាល់សំណើផ្សេងៗពីសមាគម នឹងត្រូវបានផ្តល់ចម្លើយពីក្រសួងវិញជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីបានទទួលសំណើ។

# មាត្រា ៤

## លក្ខខណ្ឌរួម

៤.១ **លោក សួរ ម៉ាឡៃ** ដែលជានាយកប្រតិបត្តិនៃសមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ ដែលបានជ្រើសរើសជាតំណាងផ្លូវការដោយសមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ នឹងត្រូវបានផ្តល់សិទ្ធិជាតំណាងសមាគមរបស់ខ្លួន ដើម្បីធ្វើការជាមួយក្រសួងអប់រំ យុវជន និងកីឡា។

៤.២ វិសោធនកម្មជាលាយលក្ខណ៍អក្សរនៃកិច្ចព្រមព្រៀងនេះ អាចធ្វើទៅបានដោយមានការព្រមព្រៀងគ្នាទៅវិញទៅមក នឹងចុះហត្ថលេខាដោយភាគីទាំងពីរ បន្ទាប់ពីបានពិចារណារួចស្រេចហើយ។

៤.៣ កិច្ចព្រមព្រៀងនេះ អាចត្រូវបានបញ្ចប់ក្នុងស្ថានភាពបន្ទាន់ តាមការសម្រេចរួមគ្នាមួយរវាងតំណាងសមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ និងក្រសួងអប់រំ យុវជន និងកីឡា ក្រោយពីបានពិគ្រោះគ្នា និងពិចារណារួចរាល់ហើយ។

៤.៤ ក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា (នាយកដ្ឋានពាក់ព័ន្ធ) មានសិទ្ធិចុះតាមដានត្រួតពិនិត្យរាល់សកម្មភាពរបស់សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ។

៤.៥ សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ មានសិទ្ធិបញ្ឈប់សកម្មភាពភ្លាមលើកិច្ចព្រមព្រៀងនេះ ក្រោយពីបានពិភាក្សាជាមួយក្រសួងអប់រំ យុវជន និងកីឡា ប្រសិនជាពិនិត្យឃើញថា គ្មានកិច្ចសហប្រតិបត្តិការគ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងឱ្យមានប្រសិទ្ធភាព ឬសន្តិសុខនៃបុគ្គលិក ឬទ្រព្យសម្បត្តិរបស់ខ្លួនស្ថិតក្នុងគ្រោះថ្នាក់ដោយសង្គ្រាម ដោយអរិភាព ឬដោយការរំខានធ្ងន់ធ្ងរណាមួយ។

៤.៦ បន្ទាប់ពីបានពិភាក្សាជាមួយសមាគមរួច ក្រសួងអប់រំ យុវជន និងកីឡា នឹងស្នើសមាគមបញ្ឈប់ការងារចំពោះបុគ្គលណាដែលត្រូវបានវិនិច្ឆ័យថា ធ្វើឱ្យខូចកិត្តិយសក្រសួង និងបានប្រព្រឹត្តខុសនឹងក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។ ប្រសិនបើមានសំណើបែបនេះ សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ ត្រូវអនុវត្តតាមនីតិវិធីដែលបានកំណត់។

៤.៧ ក្រសួងអប់រំ យុវជន និងកីឡា មានសិទ្ធិបញ្ឈប់កិច្ចព្រមព្រៀងនេះ ប្រសិនជាតំណាងរបស់សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ ត្រូវបានវិនិច្ឆ័យឃើញថា មិនបានបំពេញតាមមាត្រា២នៃកិច្ចព្រមព្រៀងនេះ។

៤.៨ ប្រសិនរកឃើញថា សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ មិនបានគោរពតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា អាចបញ្ឈប់កិច្ចព្រមព្រៀងនេះ បន្ទាប់ពីជូនព័ត៌មានដល់សាមីសមាគមនេះរួចមក។

៤.៩ កិច្ចព្រមព្រៀងនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខា ហើយមានសុពលភាពដូចមានចែងក្នុងចំណុច ១.៤ នៃកិច្ចព្រមព្រៀងនេះ។

*កិច្ចព្រមព្រៀងនេះ រៀបចំឡើងដោយឥតកែប្រែចំនួន០២ច្បាប់ដើមជាភាសាខ្មែរ និងភាសាអង់គ្លេស ហើយអត្ថបទទាំងពីរមានតម្លៃស្មើគ្នា។ ក្នុងករណីមានការបកស្រាយខ្វែងគ្នា អត្ថបទជាភាសាខ្មែរនឹងត្រូវយក ជាគោល។*

ថ្ងៃ..................ខែ..................ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី........ខែ........ឆ្នាំ២០២០

**ហត្ថលេខី**

**តំណាងក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**
**រដ្ឋមន្ត្រី**

**តំណាងសមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ**

**សូរ ម៉ាឡៃ**
**នាយកប្រតិបត្តិ**